# ទិវាអឺរ៉ុប និងពិភពលោកប្រឆាំងនឹងទោសប្រហារជីវិត "នៅពេលដែលកម្ពុជា អាចនាំផ្លូវជាបន្តទៀត"

**រៀបរៀងដោយ**

**ឯកឧត្តម Jean-François CAUTAIN ឯកអគ្គរដ្ឋទូតនៃសហភាពអឺរ៉ុបប្រចាំកម្ពុជា**

**និង**

**លោកស្រី Wan-Hea LEE តំណាង ការិយាល័យនៃឧត្តមស្នងការ អង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា**

នៅថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១៣ នេះ ប្រជាពលរដ្ឋទូទាំងពិភពលោក នឹងទទួលស្គាល់នូវវឌ្ឍនភាព ដែលត្រូវបានសម្រេចនៅទូទាំងសកលលោកលើសេចក្តីថ្លៃថ្នូរ និងអារ្យធម៌ របស់មនុស្សដោយប្រារព្ធទិវាពិភពលោកប្រឆាំងនឹងទោសប្រហារជីវិតខួបលើកទី ១១ ។

ទោសប្រហារជីវិត ធ្វើឲ្យអន្តរាយដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស និងមិនអាចបង្រួបបង្រួមបានជាមួយ នឹងសិទ្ធិមនុស្ស ជាពិសេស សិទ្ធិសំខាន់បំផុតដែលមិនអាចរំលោភបានក្នុងចំណោមសិទ្ធិមនុស្សទាំងអស់ គឺ សិទ្ធិរស់រានមានជីវិត ។ ទោសប្រហារជីវិត តម្រូវឲ្យមានដោយមិនអាចផ្លាស់ប្តូរបាននូវប្រព្រឹត្តកម្មឃោរឃៅ អមនុស្សធម៌ និងថោកទាប ដែលជាការរំលោភបំពានលើច្បាប់អន្តរជាតិ ។ ទោសប្រហារជីវិត មិនបានធ្វើឲ្យ មានភាពកោតញញើតចំពោះការប្រព្រឹត្តដ៏ឧក្រិដ្ឋ ហើយកាអនុវត្តន៍វាត្រូវបានបង្ខិនឲ្យខូច ដោយធ្វើឲ្យមាន ភាពស្មុគស្មាញពិបាកយល់ វិសមធម៌ និងការរើសអើង ។ ការខុសឆ្គោយរបស់តុលាការ ពោលគឺការដែលមិនអាចចៀសវាងបាននៅក្នុងប្រព័ន្ធច្បាប់ណាមួយ គឺមិនអាចធ្វើឲ្យត្រឡប់មកដូចដើមវិញបានទេ ។

ហេតុដូច្នេះ វាកំពុងតែជំរុញលើកទឹកចិត្តថា និន្នាការសកលលោកឆ្ពោះទៅរកការលុបចោលទោសប្រហាជីវិតនៅបន្តជាវិជ្ជមាន ។ ក្នុងរយៈពេលជាង ២០ ឆ្នាំកន្លងទៅនេះ ចំនួនប្រទេសដែលបានលុបចោលទោសប្រហារជីវិតដោយច្បាប់ចំពោះបទឧក្រិដ្ឋទាំងអស់ បានកើនឡើងពី ៥៥ ទៅដល់ ៩៧ ។ បច្ចុប្បន្ននេះ ប្រទេសជាង ១៥០ ពោលគឺជាង ២/៣ នៃប្រទេសនៅក្នុងពិភពលោក បានលុបចោលទោសប្រហារជីវិត ឬមិនអនុវត្តវា ។ ជាលើកទីបួនកាលពីខែ ធ្នូ កន្លងមកនេះ មហាសន្និបាតអង្គការសហប្រជាជាតិ បានអនុម័តសេចក្តីសម្រេចស្តីពីការព្យួរទុកបណ្តោះអាសន្នលើការប្រើប្រាស់ទោសប្រហារជីវិត ដោយមានគោលបំណងលុបចោលវា ដែលជាថ្មីម្តងទៀតដោយមានចំនួនកើនឡើងនូវរដ្ឋដែលគាំទ្រ ក្នុងនោះរួមមានកម្ពុជាផងដែរ ។

ប៉ុន្តែយើង មិនអាចអង្គុយតែពេញចិត្តនឹងវឌ្ឍនភាពប៉ុណ្ណេះនោះទេ ។ ក្នុងនោះក៏នៅមានព្រឹត្តិការណ៍វិវត្តន៍ថ្មីៗដែលធ្វើឲ្យព្រួយបារម្ភផងដែរ ។ រដ្ឋមួយចំនួន បានបន្តការប្រហារជីវិត ក្នុងនោះរួមមានរដ្ឋ ដែលមានការព្យួរទុកបណ្តោះអាសន្ន *តាមព្រឹត្តន័យ* ដែលបានអនុវត្តជាយូរមកហើយផងដែរ ។ រដ្ឋផ្សេងទៀតបានចាប់ផ្តើមប្រើប្រាស់ឡើងវិញនូវទោសប្រហារជីវិត ឬ បានពង្រីកវិសាលភាពរបស់វានៅក្នុងច្បាប់របស់ខ្លួន ។

គឺមានតែនៅក្នុងបរិបទនេះទេដែលសម្លេងប្រឆាំងនឹងទោសប្រហារជីវិត គួរតែមានលក្ខណៈកាន់តែខ្លាំងក្លាជានិច្ច ។ មានប្រសាសន៍នៅក្នុងសមាជពិភពលោកប្រឆាំងនឹងការប្រហារជីវិតលើកទី ៥ កាលពីខែមិថុនា កន្លងមកនេះ លោកស្រី ណាវីភីឡាយ ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សបានសង្កត់ធ្ងន់ថា "វាមានលក្ខណៈសំខាន់ណាស់ថា អ្នកដឹកនាំដែលគាំទ្រការលុបចោលទោសប្រហារជីវិតជំរុញលើកទឹកចិត្តប្រទេសជិតខាង និង សម្ព័ន្ធមិត្តឲ្យដើរតាមមាគ៌ាដូចគ្នាតែមួយ ។ ទោះជាប្រទេសជាច្រើនលើសលុបអត់ប្រើប្រាស់ទោសប្រហារជីវិតបន្តទៅទៀតក៏ដោយ ក៏ប្រទេសទាំងនោះ មិននិយាយដោយមានភាពឯកច្ឆន្ទខ្លាំងក្លា និងឯកភាពគ្នាពេញលេញដែរ" ។

ព្រះរាជាណាចក្រកម្ពុជា បន្តធ្វើជាគំរូក្នុងការប្រយុទ្ធប្រឆាំងនឹងទោសប្រហារជីវិត និងអាចមានមោទនភាពណាស់ចំពោះរបៀបដែលខ្លួនបានដកស្រង់មេរៀនពីអតីតកាល និងបានក្លាយជាអ្នកលុបចោលក្នុងតំបន់ដែលត្រូវបានគោរព ទាំងដោយច្បាប់ និងភាពជឿជាក់ ។ កម្ពុជា គឺជាប្រទេសមួយដែលមានអារ្យធម៌ និងវប្បធម៌ជ្រាលជ្រៅ ។ កម្ពុជា គឺជាប្រទេសមួយក្នុងចំណោមប្រទេសតែពីរប៉ុណ្ណោះនៅក្នុងអាស៊ាន ដែលបានលុបចោលទោសប្រហារជីវិត និងមានរយៈកាលនៃការលុបចោលបន្តឥតដាច់អស់រយៈពេលយូរបំផុត ដោយហាមឃាត់ទោសប្រហារជីវិតចំពោះបទឧក្រិដ្ឋទាំងអស់ ចាប់តាំងពីឆ្នាំ ១៩៨៩ មកម្លេះ ។ ព្រះរាជាណាចក្រនោះឯង ធ្វើជាគំរូសម្រាប់តំបន់ទាំងមូល ។ នៅក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងទៅថ្មីៗនេះ រាជរដ្ឋាភិបាលកម្ពុជាបានបញ្ជាក់ពីការប្តេជ្ញាចិត្តរបស់ខ្លួនម្តងហើយម្តងទៀត ចំពោះការលុបចោលទោសប្រហារជីវិត ដោយគាំទ្រដោយជាប់លាប់ចំពោះសេចក្តីសម្រេចចំនួនបួនស្តីពីការព្យួរទុកបណ្តោះអាសន្នលើការប្រើប្រាស់ទោសប្រហារជីវិត ដែលត្រូវបានចេញដោយមហាសន្និបាតអង្គការសហប្រជាជាតិនៅក្នុងឆ្នាំ ២០០៧ ឆ្នាំ ២០០៨ ឆ្នាំ ២០១០ និងខែ ធ្នូ ឆ្នាំ ២០១២ ។ ទាំងសហភាពអឺរ៉ុប (EU) និងការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិ (UN) ទទួលបន្ទុកសិទ្ធិមនុស្ស សូមសរសើរដល់កម្ពុជាចំពោះករណីនេះ ។ យើងក៏សូមស្វាគមន៍កម្ពុជាដែលបានធ្វើឲ្យមានយ៉ាងដាច់ណាត់មិនអាចកែប្រែបាននូវគោលជំហររបស់ខ្លួនប្រឆាំង នឹងទោសប្រហារជីវិត ទាំងនៅក្នុងតំបន់ និងអន្តរជាតិ ដោយធ្វើឲ្យក្លាយទៅជាភាគីនៃពិធីសារបន្ថែមទីពីរស្តីពី ការលុបចោលជាអចិន្ត្រៃយ៍នូវទោសប្រហារជីវិតនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ។

សហភាពអឺរ៉ុប ប្រកាន់គោលជំហររឹងមាំ និងផ្អែកលើគោលសីលធម៌ប្រឆាំងនឹងទោសប្រហារជីវិត ហើយការលុបចោលវានៅទូទាំងពិភពលោក គឺជាទិសដៅសំខាន់បំផុតមួយក្នុងចំណោមទិសដៅសំខាន់បំផុតជាច្រើននៃគោលនយោបាយសិទ្ធិមនុស្សរបស់ខ្លួន ។ កាលពីថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១០ លោកស្រី

Catherine Ashton តំណាងជាន់ខ្ពស់ទទួលបន្ទុកកិច្ចការបរទេស និងគោលនយោបាយសន្តិសុខរបស់សហភាពអឺរ៉ុប និងជាអនុប្រធានគណៈកម្មការសហគមន៍អឺរ៉ុប បានប្រកាសតាមរយៈសុន្ទរកថារបស់គាត់នៅក្នុងសភាអឺរ៉ុបថាៈ "ដោយសម្លឹងមើលទៅអនាគតកាល ខ្ញុំចង់ឃើញអ្វីជាច្រើនច្រើនទៀតដែលយើងអាចធ្វើបានដើម្បីគាំទ្រការលុបចោលទោសប្រហារជីវិតនៅទូទាំងពិភពលោក ។ ខ្ញុំចង់ធានារ៉ាប់រងចំពោះសភានេះថា ការងារលុបចោលទោសប្រហារជីវិតនេះ គឺជាអាទិភាពផ្ទាល់សម្រាប់ខ្ញុំ ។ ហើយខ្ញុំនឹងធ្វើឲ្យប្រាកដថា ការងារមានភាពជឿនលឿនទៅមុខ ទាំងទ្វេភាគី និងនៅក្នុងវេទិកាពហុភាគី ដោយចាប់ផ្តើមជាមួយនឹងអង្គការសហប្រជាជាតិកាលពីខែ កញ្ញា" ។

នៅទូទាំងពិភពលោក សហភាពអឺរ៉ុប ពួតដៃគ្នាជាមួយនឹងអង្គការអន្តរជាតិ និងអង្គ/គណៈពហុភាគីដែលមានលក្ខណៈសកម្មក្នុងការលើកកម្ពស់ការលុបចោលទោសប្រហារជីវិត ជាពិសេស ប្រព័ន្ធនៃអង្គការសហប្រជាជាតិ ។ ទាំងរួមគ្នា និងដោយឡែកពីគ្នា អង្គការសហប្រជាជាតិនិងសហភាពអឺរ៉ុប គាំទ្រការខិតខំប្រឹងប្រែងក្នុងការដាក់កំហិតលក្ខខណ្ឌលើការប្រើប្រាស់ កំណត់អំពីការព្យួរទុកបណ្តោះអាសន្ន និងលុបចោលជាអចិន្ត្រៃយ៍ នូវទោសប្រហារជីវិត ។

ដោយគួរឲ្យសោកស្តាយ ប្រទេសអាស៊ាន បន្តរក្សាគោលនយោបាយផ្សេងគ្នា នៅពេលវាទៅដល់ទោសប្រហារជីវិត ។ ពាក់កណ្តាលនៃសមាជិកអាស៊ានបានលុបចោលវានៅក្នុងច្បាប់ ពោលគឺមានប្រទេសកម្ពុជា និងភីលីពីន ឬ នៅក្នុងការអនុវត្តជាក់ស្តែង ពោលគឺមាន ប្រទេសមីយ៉ាន់ម៉ា ឡាវ និងប្រ៊ុយណេដារូសាឡាម ។ ប៉ុន្តែពាក់កណ្តាលទៀត គឺនៅតែជាអ្នករក្សាទុកនៅឡើយ ទោះជាប្រទេសសឹង្ហបូរីដែលស្ថិតនៅក្នុងចំណោមប្រទេសទាំងនោះ បានប្រតិបត្តិតាមការព្យួរទុកបណ្តោះអាសន្នរយៈពេលខ្លី មុននឹងដាក់ចេញនូវការដាក់កំហិតលក្ខខណ្ឌខ្លះលើការប្រើប្រាស់ទោសប្រហារជីវិតក៏ដោយ ។ ជាងពេលមុនៗ សហភាពអឺរ៉ុប និងការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា លើកបញ្ជាក់ឡើងវិញអំពីការវាយតម្លៃខ្ពស់របស់ខ្លួន លើការគាំទ្ររបស់កម្ពុជាចំពោះការព្យួរទុកបណ្តោះអាសន្នជាសកល ។ យើងជំរុញលើកទឹកចិត្តឲ្យព្រះរាជាណាចក្រនេះធ្វើជាអ្នកដឹកនាំនៅក្នុងការធ្វើការងារលើការព្យួរទុកបណ្តោះអាសន្ននៅក្នុងតំបន់នូវទោសប្រហារជីវិតនៅក្នុងក្របខ័ណ្ឌអាស៊ាន ។

## ឯកសារថ្មីសំខាន់ៗៈ

សហភាពអឺរ៉ុប

[http://eeas.europa.eu/human_rights/guidelines/death_penalty/docs/guidelines_death_penalty_st08416_en.pdf](http://eeas.europa.eu/human_rights/guidelines/death_penalty/docs/guidelines_death_penalty_st08416_en.pdf)

អង្គការសហប្រជាជាតិ

"ការចាកចេញពីទោសប្រហារជីវិត ជាមេរៀនពីបទពិធន៍ជាតិ" របាយការណ៍របស់ការិយាល័យឧត្តមស្នងការសិទ្ធិមនុស្សស្តីពីកិច្ចប្រជុំសកលលើកដំបូងលើការលប់បំបាត់ទោសប្រហារជីវិតថ្ងៃទី ៣ ខែកក្កដា ឆ្នាំ២០១២ ទីក្រុងញូវយ៉ក

របាយការណ៍ A/67/226 ចុះថ្ងៃទី ៣ ខែ សីហា ឆ្នាំ ២០១២ របស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិជូន ចំពោះមហាសន្និបាតអង្គការសហប្រជាជាតិៈ "ការព្យួរទុកបណ្ដោះអាសន្នលើការប្រើប្រាស់ទោសប្រហារជីវិត" ។

សេចក្ដីសម្រេចលេខ A/RES/67/176 ស្ដីពី "ការព្យួរទុកបណ្ដោះអាសន្នលើការប្រើប្រាស់ទោសប្រហារជីវិត" របស់មហាសន្និបាតអង្គការសហប្រជាជាតិ ដែលត្រូវបានអនុម័ត នៅថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១២ ។

របាយការណ៍ A/HRC/24/18 ចុះថ្ងៃទី ១ ខែ កក្កដា ឆ្នាំ ២០១៣ របស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិជូន ចំពោះក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិៈ "បញ្ហានៃទោសប្រហារជីវិត" ។